ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០.០.៤........អបស.មក

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៦..

# ប្រកាស

## ស្តីពី

## បែបបទនិងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង នៃមជ្ឈមណ្ឌលកែសម្ផស្ស និង មជ្ឈមណ្ឌលថែរក្សាសម្ផស្ស

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រក/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា

និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## ស ម្រេ ច

ប្រការ ១.-

ការបើក ការបិទ ការប្តូរទីតាំង ការកែទ្រង់ទ្រាយ ការប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ការប្តូរនាមករណ៍ នៃមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរសព្ទ-ទូរសារ: (៨៥៥-២៣) ៨២៦ ០៣៤ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

ប្រការ ២.-

អាចមានសិទ្ធិសុំបើកមជ្ឈមណ្ឌលកែសម្ផស្សបាន សាមីជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រជាវេជ្ជបណ្ឌិតដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមិនស្ថិតក្នុងក្របខ័ណ្ឌរដ្ឋ

-មិនជាប់ក្នុងបញ្ជីថ្កោលទោសពីបទឧក្រិដ្ឋណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ប្រការ ៣.-

សំណុំលិខិតសុំបើកមជ្ឈមណ្ឌលកែសម្ផស្សមាន :

| | |
|---|---|
| ១-ពាក្យសុំបើក "មានគំរូ" | ០១ច្បាប់ |
| ២-ច្បាប់ថតចម្លងសញ្ញាប័ត្រវេជ្ជបណ្ឌិត | ០១ច្បាប់ |
| ៣-ប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" | ០១ច្បាប់ |
| ៤-វិញ្ញាបនបត្រសុខភាព | ០១ច្បាប់ |
| ៥-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈគ្រូពេទ្យ | ០១ច្បាប់ |
| ៦-លិខិតថ្កោលទោសថ្មី ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌ | ០១ច្បាប់ |
| ៧-គំនូសបំព្រួញទីតាំងមជ្ឈមណ្ឌលកែសម្ផស្ស ដោយមានបញ្ជាក់ពីឃុំ/សង្កាត់ | ០១ច្បាប់ |
| ៨-រូបថតអគារ (ថតពីមុខ និងខាងក្នុង) | ០៥សន្លឹក |
| ៩-រូបថតសាមីជន ៤ x ៦ ស.ម | ០៧សន្លឹក |

សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ចំពោះការសុំបើកសាខានៃមជ្ឈមណ្ឌលកែសម្ផស្ស ត្រូវអនុវត្តតាមបែបបទ និងល័ក្ខខ័ណ្ឌដូចគ្នា នឹងការស្នើសុំបើកមជ្ឈមណ្ឌលកែសម្ផស្សដែរ ។ សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរ សុខាភិបាល រាជធានី-ខេត្ត ។

ប្រការ ៤.-

អាចមានសិទ្ធិសុំបើកមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខាបាន សាមីជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

-មានសញ្ជាតិខ្មែរ

-មានវិញ្ញាបនប័ត្របណ្តុះបណ្តាលអំពីការងារថែរក្សាសម្ផស្សមានរយៈពេលយ៉ាងតិច ០៣ខែ ពីសាលាបណ្តុះបណ្តាលដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច

-មិនជាប់ក្នុងបញ្ជីថ្កោលទោសពីបទឧក្រិដ្ឋណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ប្រការ ៥.-

សំណុំលិខិតសុំបើកមជ្ឈមណ្ឌលថែរក្សាសម្ផស្សមាន :

| | |
|---|---|
| ១-ពាក្យសុំបើក "មានគំរូ" | ០១ច្បាប់ |
| ២-ច្បាប់ថតចម្លងសញ្ញាប័ត្របណ្តុះបណ្តាលអំពីការងារថែរក្សាសម្ផស្ស | ០១ច្បាប់ |
| ៣-ប្រវត្តិសង្ខេបរបស់សាម៉ីជន "មានគំរូ" | ០១ច្បាប់ |
| ៤-វិញ្ញាបនបត្រសុខភាព | ០១ច្បាប់ |
| ៥-គំនូសបំព្រួញទីតាំងមជ្ឈមណ្ឌលថែសម្ផស្ស ដោយមានបញ្ជាក់ពីឃុំ/សង្កាត់ | ០១ច្បាប់ |
| ៦-លិខិតថ្កោលទោសថ្មី ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌ | ០១ច្បាប់ |
| ៧-រូបថតអគារ (ថតពីមុខ និងខាងក្នុង) | ០៥សន្លឹក |
| ៨-រូបថតសាម៉ីជន ៤ X ៦ ស.ម | ០៧សន្លឹក |

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ចំពោះការសុំបើកសាខានៃមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ត្រូវអនុវត្តតាមបែបបទ និងល័ក្ខខ័ណ្ឌដូចគ្នា នឹងការស្នើសុំបើកមជ្ឈមណ្ឌលថែរក្សាសម្ផស្សដែរ ។សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរ សុខាភិបាល រាជធានី-ខេត្ត ។

ប្រការ ៦.-

ការប្តូរទីតាំងនៃមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ត្រូវបំពេញសំណុំលិខិតដូចខាងក្រោមនេះ :

| | |
|---|---|
| ១-ពាក្យសុំប្តូរទីតាំង "មានគំរូ" | ០១ច្បាប់ |
| ២-ភ្ជាប់លិខិតអនុញ្ញាតបើក (ច្បាប់ដើម) | ០១ច្បាប់ |
| ៣-គំនូសបំព្រួញទីតាំងថ្មី ដោយមានបញ្ជាក់ពីឃុំ/សង្កាត់ | ០១ច្បាប់ |
| ៤-រូបថតអាគារ (ថតពីមុខ និងខាងក្នុង) យ៉ាងតិច | ០៥សន្លឹក |
| ៥-រូបថតសាម៉ីជន ៤ X ៦ ស.ម | ០៧សន្លឹក |

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៧.-

ការផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ត្រូវបំពេញសំណុំលិខិតរបស់អ្នកជំនួសដូចខាងក្រោម :

១-ពាក្យសុំផ្លាស់ប្តូរ "មានគំរូ" ០១ច្បាប់

២-សញ្ញាប័ត្រអ្នកជំនួស (ដូចមានចែងក្នុងប្រការ២ និងប្រការ៤) ០១ច្បាប់

៣-ប្រវត្តិសង្ខេបរបស់អ្នកផ្លាស់ចូល "មានគំរូ" ០១ច្បាប់

៤-វិញ្ញាបនបត្រសុខភាព ០១ច្បាប់

៥-លិខិតថ្កោលទោសថ្មី ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌ ០១ច្បាប់

៦-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈគ្រូពេទ្យ ០១ច្បាប់

៧-រូបថតសាម៉ីជន ៤ X ៦ ស.ម ០៧សន្លឹក

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៨.-

ក្រសួងសុខាភិបាល នឹងផ្តល់ចម្លើយអំពីការសុំបើក ការសុំបិទ ការប្តូរទីតាំង នៃមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ដល់សាម៉ីជនយ៉ាងយឺតបំផុតក្នុងរយៈពេល ២០ថ្ងៃ (គិតថ្ងៃធ្វើការ) ដោយគិតចាប់តាំងពីថ្ងៃបានទទួលសំណុំលិខិតគ្រប់គ្រាន់ និងត្រឹមត្រូវនៅនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ។

ប្រការ ៩.-

អ្នកគ្រប់គ្រងបច្ចេកទេសមួយរូប មានសិទ្ធិដាក់ពាក្យសុំបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា បានតែមួយកន្លែងប៉ុណ្ណោះ ។

ប្រការ ១០.-

ក្រោយពីបានទទួលលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ស្តីពីការបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា សាម៉ីជនត្រូវបើកទ្វារបម្រើសាធារណៈជនយ៉ាងយឺតបំផុតរយៈពេល០៣ខែ ។ ផុតកំណត់ខាងលើ បើមជ្ឈមណ្ឌលគ្មានដំណើរការទេនោះ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិតាមសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល ។ ក្នុងករណីមានមូលហេតុសមស្រប រយៈកាលកំណត់ខាងលើអាចពន្យាពេលបាន ០៣ខែទៀត ហើយបានតែមួយដងគត់តាមសំណើរបស់សាម៉ីជន ។

ប្រការ ១១.-

លិខិតអនុញ្ញាតស្តីពីការបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា មានសុពលភាពរយៈពេល០២ឆ្នាំ ។ ពីរខែមុនផុតកំណត់ សាម៉ីជនត្រូវដាក់ពាក្យសុំបន្តសុពលភាពឱ្យបានទាន់ពេលវេលា ។ ករណីអស់សុពលភាពក្រសួងសុខាភិបាលនឹងផ្អាកសកម្មភាពជាបណ្តោះអាសន្នរហូតដល់លិខិតអនុញ្ញាតមានសុពលភាពឡើងវិញ ។

ប្រការ ១២.-

ចំពោះលិខិតអនុញ្ញាតឱ្យបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ដែលបានអស់សុពលភាព ហើយខកខានពុំបានសុំបន្តសុពលភាពចាប់ពី០៣ខែឡើងទៅ ក្រសួងសុខាភិបាលពុំអនុញ្ញាតឱ្យបន្តសុពលភាពបានទេ ហើយលិខិតអនុញ្ញាតនឹងត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ១៣.-

មជ្ឈមណ្ឌលកែសម្ផស្ស ឬសាខា ត្រូវដាច់ចេញពីកន្លែងស្នាក់នៅ មានអនាម័យស្អាតបាតទាំងខាងក្នុង ទាំងខាងក្រៅ ស្របតាមការកំណត់ដូចខាងក្រោម :

១-ត្រូវមានស្លាកសញ្ញាជាមជ្ឈមណ្ឌលកែសម្ផស្ស

២-មានកន្លែងរង់ចាំទំហំ ២៤ម $^2$

៣-មានកន្លែងពិគ្រោះទំហំយ៉ាងតិច ១៦ម $^2$

៤-គ្រែចម្ងាសម្រាប់ពិនិត្យពី ៣ ទៅ ៤

៥-មានបន្ទប់សម្រាប់វះកាត់តូចតាចទំហំយ៉ាងតិច ១៦ម $^2$ និងបំពាក់ដោយគ្រែវះកាត់ ០១គ្រឿង

៦-មានប្រអប់ប្រដាប់ប្រដាវះកាត់ និងសម្ភារៈសង្គ្រោះបន្ទាន់ត្រឹមត្រូវ

៧-មានចង្កៀងអ៊ុលត្រាវីយ៉ូឡេសម្រាប់រំងាប់មេរោគក្នុងបន្ទប់វះកាត់

៨-មានសម្ភារៈសម្លាប់មេរោគ ឬ Autoclave ឬ Etuve សម្រាប់រំងាប់មេរោគសម្ភារៈវះកាត់ មានសូលុយស្យុង Antiseptique និងចេសដេរដែលមានគុណភាពមិនហួសកាលបរិច្ឆេទ

៩-មានឱសថ និងបរិក្ខាពេទ្យប្រើប្រាស់សមស្រប

១០-មានបន្ទប់ទឹក និងបង្គន់អនាម័យត្រឹមត្រូវ

១១-មានសៀវភៅកត់ត្រាពីសកម្មភាពប្រចាំថ្ងៃ និងត្រូវផ្តល់របាយការណ៍កែសម្ផស្សរៀងរាល់ ០៣ខែ ម្តងជូនទៅនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ។

ប្រការ ១៤.-

មជ្ឈមណ្ឌលថែរក្សាសម្ផស្សឬសាខាត្រូវដាច់ចេញពីកន្លែងស្នាក់នៅ មានអនាម័យស្អាតបាតទាំងខាងក្នុង ទាំងខាងក្រៅ ស្របតាមការកំណត់ដូចខាងក្រោម :

១-ត្រូវមានស្លាកសញ្ញាជាមជ្ឈមណ្ឌលថែរក្សាសម្ផស្ស

២-មានកន្លែងរង់ចាំទំហំ ២០ម $^2$

៣-មានកន្លែងពិគ្រោះទំហំយ៉ាងតិច ១២ម $^2$

៤-គ្រែចម្ងាសម្រាប់ពិនិត្យពី ១ ទៅ ២

៥-មានគ្រឿងសម្ភាង និងបរិក្ខារប្រើប្រាស់សមស្រប

៦-មានបន្ទប់ទឹក និងបង្គន់អនាម័យត្រឹមត្រូវ

៧-មានសៀវភៅកត់ត្រាពីសកម្មភាពប្រចាំថ្ងៃ និងត្រូវផ្តល់របាយការណ៍ថែរក្សាសម្ផស្សរៀងរាល់ ០៣ខែ ម្តង ជូនទៅនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ។

ប្រការ ១៥.-

មជ្ឈមណ្ឌលកែសម្ផស្សមានសិទ្ធិដូចតទៅ :

១-កែច្រមុះ

២-វះកាត់ត្របកភ្នែក

៣-ធ្វើថ្ពាល់ឱ្យខួច

៤-កែបបូរមាត់

៥-បំបាត់ស្លាកស្នាម

៦-សាក់ភ្នែក សាក់ចិញ្ចើម សាក់បបូរមាត់ លុបសាក់

៧-បណ្តុះសក់

៨-កាត់ប្រជ្រុយ បំបាត់អាចម៍រុយ

៩-បំបាត់ភាពជ្រីវជ្រួញ បំបាត់ជ្រួញកន្ទុយភ្នែក បំបាត់ខ្មៅក្រោមភ្នែក

១០-កែសម្ផស្សដោយប្រើម៉ាស៊ីនឡាស៊ែរ ។

ប្រការ ១៦.-

មជ្ឈមណ្ឌលថែរក្សាសម្ផស្ស មានសិទ្ធិដូចតទៅ :

១-ត្រាំទឹកដោះគោ

២-ខាត់ស្បែកឱ្យសដោយប្រើឡេ

៣-បកស្បែកដោយប្រើថ្នាំពេទ្យ ឬឡេ

៤-ម៉ាស្សាមុខ

៥-ម៉ាស្សាខ្លួន

៦-ស្ទីមមុខ-ខ្លួន

៧-ព្យាបាលមុន មុខជាំ

៨-ពិនិត្យស្បែកមុខ

៩-ពិនិត្យសរសៃសក់

១០-តរោមភ្នែក

១១-ប្រើថ្នាំលេបសម្រកទម្ងន់

១២-ថែរក្សាសម្ផស្សផ្សេងៗទៀត ដោយប្រើថ្នាំពេទ្យ ឬឡេ ឬប្រើម៉ាស៊ីនស៊ីម ឬម៉ាស៊ីនឡាស៊ែរ ដោយពុំមានកែទ្រង់ទ្រាយ និងពុំមានធ្វើការវះកាត់ ។

ប្រការ ១៧.-

បញ្ញត្តិហាមឃាត់ :

១-ហាមផ្សព្វផ្សាយពាណិជ្ជកម្មដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

២-ហាមប្រើប្រាស់គ្រឿងសម្អាងដែលមានប្រភពមិនច្បាស់លាស់ ឬផលិតផលហួសកំណត់កាលប្រើប្រាស់ ឬផលិតផលដែលក្រសួងសុខាភិបាលបានហាមឃាត់

៣-ហាមប្រើប្រាស់ផលិតផលដែលលាយថ្នាំក្នុងមជ្ឈមណ្ឌលដោយគ្មានរូបមន្តត្រឹមត្រូវ

៤-ហាមប្រកបអាជីវកម្មផ្សេងៗទៀតនៅក្នុងមជ្ឈមណ្ឌល ឬសាខា ។

ប្រការ ១៨.-

ក្នុងករណីអវត្តមានរបស់អ្នកគ្រប់គ្រងបច្ចេកទេសក្នុងមជ្ឈមណ្ឌល ឬសាខា ត្រូវមានអ្នកបច្ចេកទេសសមស្រប មួយរូបមកជំនួស អ្នកជំនួសនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ការជំនួសអាចចូលជាធរមានបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

ប្រការ ១៩.-

រយៈកាលនៃការជំនួសមិនអាចលើសពី ០១ឆ្នាំ បានទេ។ ក្នុងករណីចាំបាច់ និងមានមូលហេតុសមស្រប រយៈកាលនៃការកំណត់ខាងលើអាចពន្យាបាន ០១ឆ្នាំ ទៀត តាមសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល។ បែបបទនៃការជំនួស ត្រូវអនុវត្តដូចការសុំផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេសដែរ។

ប្រការ ២០.-

មជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ដែលមានបញ្ចូលជនបរទេសមកធ្វើការជាមួយ ជនបរទេសទាំងនោះត្រូវគោរពតាមអនុក្រឹត្យលេខ៩៤អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២១.-

ក្រសួងសុខាភិបាលរក្សាសិទ្ធិ ក្នុងការដកហូតមកវិញនូវលិខិតអនុញ្ញាតបើក ប្តូរទីតាំង នៃមជ្ឈមណ្ឌល ឬសាខា ក្នុងករណីពិនិត្យឃើញថា :

១-សាមីជនអនុវត្តមិនបានត្រឹមត្រូវតាមប្រការ១-១៣-១៤-១៥-១៦-១៧-១៨ និងប្រការ២០

២-សាមីជនជាប់ក្នុងបញ្ជីថ្កោលទោសពីទោសឧក្រិដ្ឋណាមួយ។

ប្រការ ២២. -

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ២៣. -

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្ត មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ២៤. -

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម៉ម ប៊ុនហេង

ចម្លងជូន :

-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងទំនាក់ទំនងសភា-ព្រឹទ្ធសភា និងអធិការកិច្ច
-ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
-សាលារាជធានីភ្នំពេញ និងខេត្ត "ដើម្បីជ្រាបជាព័ត៌មាននិងសហការ"
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-លេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួង និងគណៈកម្មការរាជធានី និងខេត្ត លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
-នាយកដ្ឋានមន្ទីរពេទ្យ "ដើម្បីអនុវត្ត"
-នាយកដ្ឋានឱសថ
-មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្ត "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ